# ព្រឹត្តិបត្រព័ត៌មាន

## គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប)

គ.ជ.ប NEC BULLETIN

លេខ ៨ ចេញផ្សាយថ្ងៃទី១ ខែសីហា ឆ្នាំ២០២៣

Issue 8 : 1 / 8 / 2023

# ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣

(ថ្ងៃអាទិត្យ ទី២៣ ខែកក្កដា ឆ្នាំ២០២៣)

## សរុបព្រឹត្តិការណ៍ថ្ងៃបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ នាថ្ងៃអាទិត្យ ទី២៣ ខែកក្កដា ឆ្នាំ២០២៣



**ឯកឧត្តម ប្រាជ្ញ ចន្ទ ប្រធាន គ.ជ.ប**

នាល្ងាចថ្ងៃអាទិត្យ ទី២៣ ខែកក្កដា ឆ្នាំ២០២៣ វេលាម៉ោង ១៨:០០ នៅសាលប្រជុំមជ្ឈមណ្ឌលវប្បធម៌ នៃវិទ្យាស្ថានជាតិអប់រំ (NIE) ឯកឧត្តម **ប្រាជ្ញ ចន្ទ** ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានធ្វើការបូកសរុបព្រឹត្តិការណ៍ ថ្ងៃបោះឆ្នោត



**តទៅទំព័រទី២**

**មាតិកា៖** **ទំព័រ**

- សរុបព្រឹត្តិការណ៍ថ្ងៃបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ នាថ្ងៃអាទិត្យ ទី២៣ ខែកក្កដា ឆ្នាំ២០២៣ ..........១
- ចំណាប់អារម្មណ៍របស់អ្នកសង្កេតការណ៍អន្តរជាតិ អំពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ...............៥
- ប្រធាន គ.ជ.ប ទទួលជួបគណៈប្រតិភូសង្កេតការណ៍បោះឆ្នោតអន្តរជាតិ មកពីព្រះរាជាណាចក្រថៃ ..........................៩
- សរុបព្រឹត្តិការណ៍ឃោសនាបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ រយៈពេល ២១ ថ្ងៃ ................................១១
- ក្រុមអ្នកនាំពាក្យ គ.ជ.ប ជួបជាមួយក្រុមអ្នកសង្កេតការណ៍បោះឆ្នោតអន្តរជាតិ មកពីប្រទេសជប៉ុន ..........................១៥

តមកពីទំព័រទី១ **សរុបព្រឹត្តិការណ៍ ...**

ជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ នៅថ្ងៃអាទិត្យ ទី២៣ ខែកក្កដា ឆ្នាំ២០២៣។

ឯកឧត្តម **ប្រាជ្ញ ចន្ទ** បានធ្វើការបូកសរុបអំពីព្រឹត្តិការណ៍នៃថ្ងៃបោះឆ្នោត ជូនអ្នកសារព័ត៌មានជាតិ អន្តរជាតិ អ្នកសង្កេតការណ៍ជាតិ អន្តរជាតិ ព្រមទាំងភាគីពាក់ព័ន្ធដែលបានចូលរួមជាង ១០០ នាក់។

សូមដកស្រង់ និងសង្ខេបនូវចំណុចនីមួយៗដូចខាងក្រោម៖

- ការិយាល័យបោះឆ្នោតនៅទូទាំងប្រទេស ដែលមានចំនួន ២៣.៧៨៩ ការិយាល័យ បានបើកដំណើរការនៅម៉ោង ៧:០០ ព្រឹក ព្រមៗគ្នា



**ភាគីពាក់ព័ន្ធចូលរួមក្នុងកិច្ចប្រជុំ**

- ដំណើរការបោះឆ្នោតបានប្រព្រឹត្តទៅចាប់ពីម៉ោង ៧:០០ ព្រឹកហូតដល់ម៉ោង ៣:០០ រសៀល ទោះបីមានភ្លៀងនៅតាមរាជធានី ខេត្តមួយចំនួនយ៉ាងណាក៏ដោយ ដំណើរការបោះឆ្នោត និងរាប់សន្លឹកឆ្នោតបានប្រព្រឹត្តទៅជាប្រក្រតីតាមនីតិវិធី
- ទម្រង់បែបបទលេខ ១១០២ ដែលជាកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត និងលទ្ធផលនៃការបោះឆ្នោត ត្រូវបានគណៈកម្មការការិយាល័យរាប់សន្លឹកឆ្នោតបិទផ្សាយភ្លាមៗផងដែរនៅមុខការិយាល័យរាប់សន្លឹកឆ្នោតនីមួយៗ ហើយភ្នាក់ងារគណបក្សនយោបាយបានថតរូបភាព និងចម្លងតួលេខពីកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ទ.១១០២ ដែលបិទផ្សាយ និង



**គណៈអធិបតីក្នុងកិច្ចប្រជុំជាមួយភាគីពាក់ព័ន្ធ**

បានទៅទទួលយកទម្រង់បែបបទលេខ ១១០២ នៅទីស្នាក់ការគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត (គឃ.សប) នោះ

- អ្នកបានចេញទៅបោះឆ្នោតសរុបទូទាំងប្រទេស មានចំនួន ៨.២១៤.៤៣០ នាក់ ស្មើនឹង ៨៤,៥៩% (តួលេខបណ្តោះអាសន្ន) នៃអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ចំនួន ៩.៧១០.៦៥៥ នាក់។

ការបោះឆ្នោតបានប្រព្រឹត្តទៅដោយតម្លាភាព ស្ថិតក្រោមការឃ្លាំមើលរបស់ភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍ជាតិ អន្តរជាតិ រួមទាំងអ្នកសារព័ត៌មានជាតិ និងអន្តរជាតិ ដែលមានចំនួនដូចខាងក្រោម៖

- គណបក្សនយោបាយចំនួន ៨ បានដាក់ភ្នាក់ងារសរុបចំនួន ៥៧.០១២ នាក់ (ស្ត្រី ១៦.៦២៤ នាក់) ដើម្បីសង្កេតមើលការបោះឆ្នោតនៅតាមការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត
- អ្នកសង្កេតការណ៍ជាតិសរុប ចំនួន ៨៩.៥៦២ នាក់ (ស្ត្រី ៥២.៦៥២ នាក់) មកពី ១៣៤ សមាគម និង



**ភាគីពាក់ព័ន្ធចូលរួមក្នុងកិច្ចប្រជុំ**

អង្គការមិនមែនរដ្ឋាភិបាល

- អ្នកសង្កេតការណ៍អន្តរជាតិសរុប ចំនួន ៦០៤ នាក់ មកពី ៦១ ស្ថាប័ន (ក្នុងនោះភ្ញៀវពិសេស មានចំនួន ១៨ នាក់ មកពី ១០ ស្ថាប័ន និងអ្នកបកប្រែសម្រាប់អ្នកសង្កេតការណ៍អន្តរជាតិ ចំនួន ១៨២ នាក់)
- អ្នកសារព័ត៌មានជាតិ ចំនួន ១.២៨៩ នាក់ (ស្ត្រី ១៨៥ នាក់) មកពី ១២៧ អង្គភាព និងអ្នកសា-ព័ត៌មានអន្តរជាតិ ចំនួន ១៣៧ នាក់ (ស្ត្រី ៣០ នាក់) មកពី ៣៨ អង្គភាព។



ភាគីពាក់ព័ន្ធមានចំណាប់អារម្មណ៍ និងសំណួរក្នុងកិច្ចប្រជុំ

ឯកឧត្តមប្រធាន គ.ជ.ប បានជម្រាបជូនអំពីសភាព-ការណ៍មុនថ្ងៃបោះឆ្នោតថា៖

- គ.ជ.ប បានផលិតបណ្ណព័ត៌មានអ្នកបោះឆ្នោតសរុប ចំនួន ៩.៧១០.៦៥៥ សន្លឹក ហើយបណ្ណព័ត៌មានទាំងនេះត្រូវបាន គឃ.សប ចែកជូនដល់អ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោតបានសរុប ចំនួន ៩.២០៩.១៧៧ សន្លឹក ស្មើនឹង ៩៤.៨៤ ភាគរយ
- គឃ.សប និងអាជ្ញាធរឃុំ សង្កាត់ បានចេញឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត (ឯ.អ) ជូនប្រជាពលរដ្ឋសរុបមានចំនួន ២០១.៧៧៨ នាក់
- ទីតាំងការិយាល័យបោះឆ្នោត ចំនួន ១០ នៃខេត្តបន្ទាយមានជ័យ ខេត្តកំពង់ស្ពឺ ខេត្តកោះកុង ខេត្តពោធិ៍សាត់ ខេត្តតាកែវ និងខេត្តប៉ៃលិន ត្រូវបានផ្លាស់ប្តូរផ្អែកតាមសំណើរបស់អាជ្ញាធរឃុំ សង្កាត់ ដោយមានការឯកភាពពីគណៈកម្មការឃុំ សង្កាត់រៀបចំការបោះ-



សកម្មភាពក្នុងកិច្ចប្រជុំជាមួយភាគីពាក់ព័ន្ធ

ឆ្នោតពាក់ព័ន្ធ និងតំណាងគណបក្សនយោបាយឈរ-ឈ្មោះបោះឆ្នោត និងត្រូវបានជូនដំណឹង ឬផ្សព្វផ្សាយយ៉ាងទូលំទូលាយដល់ប្រជាពលរដ្ឋ និងភាគីពាក់ព័ន្ធផងដែរ មុនថ្ងៃបោះឆ្នោត។

ឯកឧត្តមប្រធាន បានជម្រាបជូនអំពីសភាពការណ៍មុនថ្ងៃបោះឆ្នោតបន្តទៀតថា មានករណីភ្លៀងធ្លាក់ខ្លាំង និងមានអគ្គិភ័យបណ្តាលឱ្យខូចខាតសម្ភារ ឯកសារបោះឆ្នោត មួយចំនួនដែលមានទីតាំងដូចខាងក្រោម៖

- នៅគណៈកម្មការរៀបចំការបោះឆ្នោតសង្កាត់ទឹកល្អក់ទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ មានទឹកលេចបណ្តាលឱ្យខូចខាតទាំងស្រុងនូវសម្ភារការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ចំនួន ៤ កេស និងកេស គឃ.សប ចំនួន ១ កេស សរុបចំនួន ៥ កេស
- នៅគណៈកម្មការរៀបចំការបោះឆ្នោតសង្កាត់កន្ទោក ខណ្ឌកំបូល រាជធានីភ្នំពេញ មានទឹកលេចបណ្តាលឱ្យខូចខាតទាំងស្រុងនូវសម្ភារការិយាល័យបោះឆ្នោត



ភាគីពាក់ព័ន្ធមានចំណាប់អារម្មណ៍ និងសំណួរក្នុងកិច្ចប្រជុំ



**ភាគីពាក់ព័ន្ធមានចំណាប់អារម្មណ៍ និងសំណួរក្នុងកិច្ចប្រជុំ**

និងរាប់សន្លឹកឆ្នោត ចំនួន ៤ កេស

- នៅឃុំព្រែកតាមាក់ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល មានករណីអគ្គិភ័យឆេះផ្ទះរបស់សមាជិកគណៈកម្មការឃុំរៀបចំការបោះឆ្នោត ទទួលបន្ទុកលើការងាររដ្ឋបាល បណ្ដាលឱ្យខូចខាតសម្ភារកុំព្យូទ័រមួយចំនួន។

ហើយករណីខាងលើនេះ ត្រូវបាន គ.ជ.ប ចាត់វិធានការដោះស្រាយភ្លាមៗ ដោយបានផ្ដល់សម្ភារ បរិក្ខារថ្មីជំនួសជូនគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតពាក់ព័ន្ធ។

អំពីសភាពការណ៍សន្តិសុខមុនថ្ងៃបោះឆ្នោត និងនៅថ្ងៃបោះឆ្នោត ឯកឧត្ដម **ប្រាជ្ញ ចន្ទ** បានបញ្ជាក់ជូនថា៖

- គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍នៃការបោះឆ្នោត និង គ.ជ.ប បានដាក់ចេញនូវសេចក្ដីណែនាំរួមស្ដីពីសកម្មភាព និងការរៀបចំភ្នាក់ងារសន្តិសុខបោះឆ្នោតក្នុងយុទ្ធនាការការពារដំណើរការរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ដើម្បីគ្រប់គ្រងស្ថានការណ៍ និងធានាឱ្យការបោះឆ្នោតដំណើរការរលូនល្អ និងប្រកបដោយសន្តិសុខ និងសុវត្ថិភាព



**ភាគីពាក់ព័ន្ធមានចំណាប់អារម្មណ៍ និងសំណួរក្នុងកិច្ចប្រជុំ**

- មានការញុះញង់តាមបណ្ដាញសង្គមមិនឱ្យប្រជាពលរដ្ឋទៅបោះឆ្នោត ឬឱ្យគូសបំផ្លាញសន្លឹកឆ្នោតចោល ត្រូវបាន គ.ជ.ប និងភាគីពាក់ព័ន្ធជាច្រើនបានអំពាវនាវដល់ប្រជាពលរដ្ឋអ្នកបោះឆ្នោតកុំធ្វើតាមការញុះញង់ខុសច្បាប់ និងសូមឱ្យអញ្ជើញទៅបោះឆ្នោតគ្រប់គ្នា
- មានបណ្ដឹងមួយចំនួនដែល គ.ជ.ប នឹងដោះស្រាយតាមច្បាប់។



**ភាគីពាក់ព័ន្ធមានចំណាប់អារម្មណ៍ និងសំណួរក្នុងកិច្ចប្រជុំ**

ជារួម ឯកឧត្ដម **ប្រាជ្ញ ចន្ទ** បានវាយតម្លៃថា ដំណើរការបោះឆ្នោតបានប្រព្រឹត្តទៅដោយជោគជ័យ និងក្នុងបរិយាកាសស្ងប់ស្ងាត់ មានសន្តិសុខ សុវត្ថិភាព និងសណ្ដាប់ធ្នាប់សាធារណៈ គ្មានអំពើហិង្សា គ្មានការគំរាមកំហែង ដោយមានកិច្ចសហការល្អពីសំណាក់យន្តការ និងរចនាសម្ព័ន្ធសន្តិសុខបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ជាមួយ គ.ជ.ប និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់។

អំពីការផ្សព្វផ្សាយលទ្ធផលបឋមនៃការបោះឆ្នោត ឯកឧត្ដមប្រធាន គ.ជ.ប បានមានប្រសាសន៍ថា នៅយប់ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣ ដែលជាថ្ងៃបោះឆ្នោត គ.ជ.ប ប្រកាសផ្សាយលទ្ធផលបឋមនៃការបោះឆ្នោត ចាប់ពីម៉ោង ៧ យប់ តទៅ។ ការប្រកាសផ្សាយនេះមានគោលបំណង៖

- ដើម្បីផ្ដល់ជំនឿទុកចិត្តដល់ភាគីពាក់ព័ន្ធទៅលើលទ្ធផលនៃការបោះឆ្នោត

- ដើម្បីផ្សព្វផ្សាយលទ្ធផលបឋមបានឆាប់រហ័ស ត្រឹមត្រូវច្បាស់លាស់ ទូលំទូលាយ និងមានតម្លាភាព
- ដើម្បីពង្រឹងប្រសិទ្ធភាព និងពង្រីកវិសាលភាពប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ក្នុងដំណើរការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោត។

គ.ជ.ប បានសហការជាមួយអគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា (ទ.ទ.ក) ដោយយកទិន្នន័យតាមទម្រង់បែបបទលេខ ១១០៨ និងទម្រង់បែបបទលេខ ១១០២ ពីគណៈកម្មការឃុំសង្កាត់រៀបចំការបោះឆ្នោត និងបន្ទាប់ពីគណៈកម្មការគ្រប់គ្រងលទ្ធផលបឋម សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ របស់ គ.ជ.ប បានត្រួតពិនិត្យ និងផ្ទៀងផ្ទាត់បានត្រឹមត្រូវហើយ ដើម្បីផ្សព្វផ្សាយ។ លទ្ធផលបឋមនៃការបោះឆ្នោតនេះ មានផ្សាយបន្តផ្ទាល់តាមទូរទស្សន៍ជាតិកម្ពុជា វិទ្យុជាតិ ទីភ្នាក់ងារសារព័ត៌មានកម្ពុជា តាមគេហទំព័រ និងបណ្តាញសង្គមផ្លូវការរបស់ គ.ជ.ប។ ប្រព័ន្ធផ្សព្វផ្សាយឯកជនអាចតំណភ្ជាប់ពីទូរទស្សន៍ជាតិកម្ពុជា និងវិទ្យុជាតិ បានផងដែរ។

បន្ទាប់មក គ.ជ.ប បានឆ្លើយទៅនឹងសំណួរជាច្រើនរបស់អ្នកចូលរួមក្នុងព្រឹត្តិការណ៍យប់ ថ្ងៃអាទិត្យ ទី២៣ ខែកក្កដា ឆ្នាំ២០២៣ នោះយ៉ាងក្បោះក្បាយតាមច្បាប់ និងនីតិវិធីនៃការបោះឆ្នោត។

មុននឹងបញ្ចប់ ឯកឧត្តម **ប្រាជ្ញ ចន្ទ** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះប្រជាពលរដ្ឋទាំងអស់ដែលបានចូលរួមការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ដែលជាតំណាងរបស់ប្រជាពលរដ្ឋក្នុងការដឹកនាំការអភិវឌ្ឍប្រទេស និងលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ សេរីពហុបក្សនៅព្រះរាជាណាចក្រកម្ពុជា និងបានថ្លែងអំណរគុណចំពោះគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ ភ្នាក់ងារសន្តិសុខបោះឆ្នោតទាំងអស់ អាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ មន្ត្រីបោះឆ្នោតគ្រប់លំដាប់ថ្នាក់ គណបក្សនយោបាយ អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ និងភាគីពាក់ព័ន្ធទាំងអស់ដែលបានចូលរួម និងសហការអនុវត្តតាមភារកិច្ចរៀងៗខ្លួន ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។ ឯកឧត្តម បានបន្តថា នេះជាការរួមចំណែកធ្វើឱ្យការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ នេះ ប្រព្រឹត្តទៅដោយជោគជ័យ និងប្រកបដោយសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ គ្មានអំពើហិង្សា គ្មានការគំរាមកំហែង និងសូមបន្តរក្សាភាពស្ងប់ស្ងាត់ ដើម្បីបង្កបរិយាកាសល្អក្រោយថ្ងៃបោះឆ្នោត និងរង់ចាំការប្រកាសលទ្ធផលផ្លូវការនៃការបោះឆ្នោតដោយ គ.ជ.ប។

តាមប្រតិទិននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ លទ្ធផលផ្លូវការនៃការបោះឆ្នោតនឹងត្រូវប្រកាសផ្សាយនៅចន្លោះពីថ្ងៃទី៩ ខែសីហា ដល់ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០២៣ (តាមករណីគ្មាន ឬមានពាក្យបណ្តឹង និងករណីគ្មានការបោះឆ្នោតសាជាថ្មី)៕

# ចំណាប់អារម្មណ៍របស់អ្នកសង្កេតការណ៍អន្តរជាតិ អំពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ថ្ងៃអាទិត្យ ទី២៣ ខែកក្កដា ឆ្នាំ២០២៣

បន្ទាប់ពីបញ្ចប់ការបោះឆ្នោត ឯកឧត្តម **នុត សុខុម** អនុប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានដឹកនាំកិច្ចប្រជុំជាមួយអ្នកសង្កេតការណ៍បោះឆ្នោតអន្តរជាតិ នាព្រឹកថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៣ វេលាម៉ោង ៩:០០ នៅសណ្ឋាគារសូហ្វីតែល ភ្នំពេញ ភូគីត្រា ក្នុងរាជធានីភ្នំពេញ។

ជាកិច្ចចាប់ផ្តើម ឯកឧត្តម **នុត សុខុម** បានថ្លែងអំណរ-



ឯកឧត្តម នុត សុខុម អនុប្រធាន គ.ជ.ប

គុណចំពោះអ្នកសង្កេតការណ៍អន្តរជាតិទាំងអស់ ហើយមានចំណាប់អារម្មណ៍ និងបានសង្ខេបព្រឹត្តិការណ៍នៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ នៅថ្ងៃអាទិត្យ ទី២៣ ខែកក្កដា ឆ្នាំ២០២៣ ថា ការិយាល័យបោះឆ្នោតនៅទូទាំងប្រទេស ដែលមានចំនួន ២៣.៧៨៩ ការិយាល័យ បានបើកដំណើរការទាំងអស់ ហើយអ្នកដែលបានចេញទៅបោះឆ្នោតសរុបទូទាំងប្រទេស មានចំនួន ៨.២១៤.៤៣០ នាក់ ស្មើនឹង ៨៤,៥៩% (តួលេខបណ្តោះអាសន្ន) នៃអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោតចំនួន ៩.៧១០.៦៥៥ នាក់។ ឯកឧត្តមបានវាយតម្លៃថា ជាទូទៅការបោះឆ្នោតប្រកបដោយសេរី យុត្តិធម៌ ស្ថិតក្នុងបរិយាកាសស្ងប់ស្ងាត់សន្តិភាពគ្មានអំពើហិង្សានិងប្រព្រឹត្តទៅដោយរលូន។ បន្ទាប់មកឯកឧត្តមបានផ្តល់ឱកាសដល់អ្នកសង្កេតការណ៍បោះឆ្នោតអន្តរជាតិ ដែលមានវត្តមាននៅក្នុងកិច្ចប្រជុំនោះ មានចំណាប់អារម្មណ៍លើដំណើរការបោះឆ្នោតជ្រើសតាំងតំណាង-រាស្ត្រ នីតិកាលទី៧។

ចំណាប់អារម្មណ៍របស់ ឯកឧត្តម **វ៉ាង វិនធៀន** (H.E. Mr. Wang Wentian) ឯកអគ្គរដ្ឋទូត សាធារណរដ្ឋប្រជាមានិត-ចិន ដែលបានសង្កេតឃើញដូចខាងក្រោម៖

- ការរៀបចំការបោះឆ្នោតប្រកបដោយវិជ្ជាជីវៈ និងសូមអបអរសាទរចំពោះប្រជាពលរដ្ឋកម្ពុជា ដែលបានសម្តែងនូវឆន្ទៈ និងការអនុវត្តសិទ្ធិរបស់ខ្លួន ដោយចេញទៅបោះឆ្នោតមានចំនួនយ៉ាងច្រើនបានដល់ ៨៤,៥៩%
- ដំណើរការបោះឆ្នោត និងរាប់សន្លឹកឆ្នោត បានប្រព្រឹត្តទៅស្របតាមច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា



សកម្មភាពក្នុងកិច្ចប្រជុំ



សកម្មភាពក្នុងកិច្ចប្រជុំ

- គណបក្សនយោបាយទាំង ១៨ បានធ្វើការឃោសនាបោះឆ្នោតដោយសេរី នៅទូទាំងប្រទេស ក្នុងរយៈពេល ២១ ថ្ងៃកន្លងមកនេះ។ ប្រជាពលរដ្ឋទទួលបានព័ត៌មានគ្រប់គ្រាន់ ក្នុងការជ្រើសរើសគណបក្សនយោ-បាយដែលខ្លួនពេញចិត្ត
- លទ្ធផលនៃការបោះឆ្នោត គឺអាចទទួលយកបាន
- ប្រទេសចិនសូមគាំទ្រនូវជម្រើសរបស់ប្រជាជនកម្ពុជា ក្នុងការការពារឯករាជ្យ និងអធិបតេយ្យភាពរបស់ខ្លួន ដោយមិនមានការជ្រៀតជ្រែកពីភាគីបរទេស។

ចំណាប់អារម្មណ៍របស់ឯកឧត្តម **យូថេន សូ** (H.E.Mr. U Thein Soe) ប្រធានគណៈកម្មការ រៀបចំការបោះឆ្នោតនៃប្រទេសមីយ៉ាន់ម៉ា ដែលបានសង្កេតឃើញដូចខាងក្រោម ៖

- ឃើញស្នាមញញឹមរបស់ប្រជាពលរដ្ឋកម្ពុជាដែលបានអនុវត្តសិទ្ធិរបស់ខ្លួន ក្នុងការចេញទៅបោះឆ្នោតយ៉ាងច្រើន។ កែវភ្នែករបស់ប្រជាពលរដ្ឋកម្ពុជា បានរួម

ចំណែកក្នុងការតម្រង់ទិសប្រទេសជាតិរបស់ខ្លួន

- ការបោះឆ្នោតមានសារៈសំខាន់ ហើយមានលក្ខណៈល្អសម្រាប់ព្រះរាជាណាចក្រកម្ពុជា ក្នុងរយៈពេលជាច្រើនឆ្នាំទៅមុខទៀត
- គណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់របស់ព្រះរាជាណាចក្រកម្ពុជា បានប្រឹងប្រែងរៀបចំការបោះឆ្នោតប្រកបដោយជោគជ័យ។

ចំណាប់អារម្មណ៍របស់ ឯកឧត្តម **នែលស៊ុន ជេសែលីស** (H.E.Mr. Nelson J.Celis) សមាជិកគណៈកម្មការរៀបចំការបោះឆ្នោតនៃសាធារណរដ្ឋហ្វីលីពីន ដែលបានសង្កេតឃើញដូចខាងក្រោម៖



**សកម្មភាពក្នុងកិច្ចប្រជុំ**

- ភាគរយនៃអ្នកបោះឆ្នោត ៨៤,៥៩% នៅព្រះរាជាណាចក្រកម្ពុជា ខ្ពស់ជាងនៅប្រទេសហ្វីលីពីន ដែលមានត្រឹមតែ ៨៣% ប៉ុណ្ណោះក្នុងការបោះឆ្នោតឆ្នាំ២០២២ កន្លងទៅនេះ
- ប្រជាពលរដ្ឋកម្ពុជាមានការចាប់អារម្មណ៍ខ្ពស់ ក្នុងការជ្រើសរើសថ្នាក់ដឹកនាំប្រទេសជាតិ របស់ខ្លួនប្រកបដោយភាពត្រឹមត្រូវ
- ការបោះឆ្នោតមានតម្លាភាព។ ការរាប់សន្លឹកឆ្នោតដោយដៃ មានលំដាប់លំដោយ ហើយបញ្ជូនលទ្ធផលពីការិយាល័យបោះឆ្នោត មកគណៈកម្មការរៀបចំការបោះឆ្នោតតាមលំដាប់ថ្នាក់ និងតាមប្រព័ន្ធអេឡិចត្រូនិក ដែលបញ្ជាក់អំពីតម្លាភាពយ៉ាងខ្លាំង គួរឱ្យជឿទុកចិត្តបាន



**សកម្មភាពក្នុងកិច្ចប្រជុំ**

- អបអរសាទរចំពោះព្រះរាជាណាចក្រកម្ពុជា ក្នុងការរៀបចំការបោះឆ្នោតប្រកបដោយជោគជ័យ សន្តិភាព និងគ្មានអំពើហិង្សា។

ចំណាប់អារម្មណ៍របស់ ឯកឧត្តម **ម៉ាស៊ូរីស្គី កុងស្តាន់ទីន** (H.E.Mr. Mazurevskiy Konstantin) សមាជិកគណៈកម្មការរៀបចំការបោះឆ្នោតនៃសហព័ន្ធរុស្ស៊ី ដែលបានសង្កេតឃើញដូចខាងក្រោម៖

- ការរៀបចំការិយាល័យបោះឆ្នោតមានរបៀបរៀបរយ ដោយមានបិទបញ្ជីឈ្មោះអ្នកបោះឆ្នោតភ្ជាប់ជាមួយរូបថត បិទនៅខាងមុខការិយាល័យបោះឆ្នោត
- នៅថ្ងៃបោះឆ្នោត អ្នកបោះឆ្នោតបានកាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងបណ្ណព័ត៌មានអ្នកបោះឆ្នោត បង្ហាញមន្ត្រីការិយាល័យបោះឆ្នោត ដែលការងារនេះជួយពន្លឿនក្នុងការរកឈ្មោះនៅក្នុងបញ្ជីបោះឆ្នោត ដើម្បីធ្វើឱ្យការបោះឆ្នោតប្រព្រឹត្តទៅបានឆាប់រហ័ស
- ការរៀបចំសម្ភារក្នុងការិយាល័យបោះឆ្នោត មានបន្ទប់



**សកម្មភាពប្រជាពលរដ្ឋមកបោះឆ្នោត**



**សកម្មភាពប្រជាពលរដ្ឋមកបោះឆ្នោត**

សម្ងាត់ ហិបឆ្នោត ទឹកខ្មៅជ្រលក់ម្រាមដៃ ដែលអ្នកបោះឆ្នោតត្រូវជ្រលក់បញ្ជាក់ថាបានបោះឆ្នោតរួចហើយ

- ស្ត្រីកម្ពុជា ក្លាហានជ្រលក់ម្រាមដៃនឹងទឹកខ្មៅលាងមិនជ្រះ ដែលជាទូទៅស្ត្រីត្រូវការម្រាមដៃស្អាត
- មន្ត្រីការិយាល័យបោះឆ្នោតមានពាក់អាវសម្គាល់ ហើយភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍បោះឆ្នោត និងអ្នកសារព័ត៌មាន មានបណ្ណសម្គាល់ខ្លួនផងដែរ។ ទាំងនេះបញ្ជាក់ថា ដំណើរការបោះឆ្នោត និងរាប់សន្លឹកឆ្នោតបានប្រព្រឹត្តទៅស្របតាមច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា។

ចំណាប់អារម្មណ៍របស់ ឯកឧត្តម **នីថេស គូម៉ា វីយ៉ាស** (H.E.Mr. Nitesh Kumar Vyas) អនុប្រធានគណៈកម្មការរៀបចំការបោះឆ្នោតនៃសាធារណរដ្ឋឥណ្ឌា ដែលបានសង្កេតឃើញដូចខាងក្រោម៖

- ទីតាំងការិយាល័យបោះឆ្នោត ផ្តល់ភាពងាយស្រួលដល់អ្នកទៅបោះឆ្នោត។ ការិយាល័យបោះឆ្នោតមាន



**សកម្មភាពប្រជាពលរដ្ឋមកបោះឆ្នោត**

ឧបករណ៍គ្រឿងសង្ហារិម មានពន្លឺ មានលំហដ៏ត្រឹមត្រូវសម្ភារបោះឆ្នោត ត្រូវបានរៀបចំជាស្រេចនៅមុនថ្ងៃបោះឆ្នោត

- អ្នកបោះឆ្នោតតាមតម្រង់ជួរដោយមានរបៀបរៀបរយនៅថ្ងៃបោះឆ្នោត
- ការចែកបណ្ណព័ត៌មានអ្នកបោះឆ្នោត បានហួតទៅដល់ ៩៤,៨៤% បង្កភាពងាយស្រួលដល់អ្នកបោះឆ្នោត
- មន្ត្រីការិយាល័យបោះឆ្នោត ទទួលបានការបណ្តុះ-បណ្តាលយ៉ាងល្អ
- ការរាប់សន្លឹកឆ្នោត មានតារាងកត់ត្រាត្រឹមត្រូវនៅចំពោះមុខភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍



**សកម្មភាពរាប់សន្លឹកឆ្នោត**

- ភាគីឥណ្ឌាសប្បាយចិត្តចំពោះការប្រើប្រាស់ទឹកខ្មៅជ្រលក់លាងមិនជ្រះប្រើក្នុងការបោះឆ្នោត
- ភាគីឥណ្ឌាអបអរសាទរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ គ.ជ.ប កម្ពុជា និងប្រជាធិបតេយ្យនៅកម្ពុជា។

ចំណាប់អារម្មណ៍របស់ ឯកឧត្តម **អាល់ស៊ីណូ ដឺអារ៉ូ បារីស** (H.E.Mr. Alcino de Araujo Baris) សមាជិកគណៈកម្មការរៀបចំការបោះឆ្នោតនៃសាធារណរដ្ឋប្រជាធិបតេយ្យទីម័រខាងកើត ដែលបានសង្កេត ឃើញដូចខាងក្រោម៖

- ការត្រៀមរៀបចំបានល្អមុនថ្ងៃបោះឆ្នោត
- ដំណើរការបោះឆ្នោត និងរាប់សន្លឹកឆ្នោតបានប្រព្រឹត្តទៅល្អ និងគ្មានអំពើហិង្សា
- ការិយាល័យបោះឆ្នោតមានសណ្តាប់ធ្នាប់ របៀបរៀប-

រយ ប្រកបដោយវិជ្ជាជីវៈ

- ប្រព័ន្ធបោះឆ្នោតនៅព្រះរាជាណាចក្រកម្ពុជា ស្រដៀងគ្នានឹងប្រព័ន្ធបោះឆ្នោតនៅសាធារណរដ្ឋប្រជាធិបតេយ្យទីម័រខាងកើត។

ជារួមគណៈប្រតិភូដែលជាអ្នកសង្កេតការណ៍បោះឆ្នោតអន្តរជាតិទាំងអស់ បានថ្លែងអំណរគុណដល់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការធ្វើទំនាក់ទំនងល្អជាមួយគ្នា និងថ្លែងអំណរគុណដល់ គ.ជ.ប កម្ពុជា ដែលបានធ្វើបដិសណ្ឋារកិច្ចយ៉ាងល្អ និងបានផ្តល់ឱកាសដល់គណៈប្រតិភូអន្តរជាតិសង្កេតមើលការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣។



សកម្មភាពរាប់សន្លឹកឆ្នោត

# ប្រធាន គ.ជ.ប ទទួលជួបគណៈប្រតិភូសង្កេតការណ៍បោះឆ្នោតអន្តរជាតិ មកពីព្រះរាជាណាចក្រថៃ

នារសៀលថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២៣ វេលាម៉ោង ៣:០០ នៅទីស្តីការគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ឯកឧត្តម **ប្រាជ្ញ ចន្ទ** ប្រធាន គ.ជ.ប បានទទួលជួបឯកឧត្តម **អ៊ីតធីផន ប៊ុនប្រាខង** (H.E.Mr. Ittiporn Boonpracong) ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតនៃព្រះរាជាណាចក្រថៃ ដែលបានដឹកនាំគណៈប្រតិភូមកសង្កេតការណ៍បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ នៅព្រះរាជាណាចក្រកម្ពុជា។



សកម្មភាពក្នុងជំនួបពិភាក្សា

ឯកឧត្តម **អ៊ីតធីផន ប៊ុនប្រាខង** បានថ្លែងអំណរគុណដល់ ឯកឧត្តម **ប្រាជ្ញ ចន្ទ** ដែលបានអញ្ជើញគណៈប្រតិភូថៃ ដើម្បីមកសង្កេតមើលការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧។ ឯកឧត្តមបានបន្តថា នេះជាលើកទីមួយហើយសម្រាប់ឯកឧត្តម ក្នុងតំណែងជាប្រធាន គ.ជ.ប នៃព្រះរាជាណាចក្រថៃ ដែលបានធ្វើទស្សនកិច្ចនៅក្រៅប្រទេស គឺព្រះរាជាណាចក្រកម្ពុជាតែម្តង ដែលមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធ និងជាសមាជិកអាស៊ានជាមួយគ្នា ហើយឯកឧត្តមមានអារម្មណ៍សប្បាយចិត្តជាងបានទៅបណ្តាប្រទេសនៅអឺរ៉ុបទៅទៀត។

ឯកឧត្តម **ប្រាជ្ញ ចន្ទ** មានមតិស្វាគមន៍ចំពោះ ឯកឧត្តម **អ៊ីតធីផន ប៊ុនប្រាខង** និងសហការីទាំងអស់ ដែលបានចាប់អារម្មណ៍ចំពោះព្រះរាជាណាចក្រកម្ពុជា និងបានអញ្ជើញមកសង្កេតការណ៍បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧នេះ។

ឯកឧត្តម **ប្រាជ្ញ ចន្ទ** បានមានប្រសាសន៍បន្តថា នៅឆ្នាំ១៩៩៣ ការបោះឆ្នោតនៅកម្ពុជា ត្រូវបានរៀបចំឡើងដោយអាជ្ញាធរបណ្តោះអាសន្ននៃអង្គការសហប្រជាជាតិ (UNTAC)។ នៅឆ្នាំ១៩៩៧ ព្រះរាជាណាចក្រកម្ពុជាបានបង្កើតស្ថាប័នរៀបចំការបោះឆ្នោត ដើម្បីរៀបចំការបោះឆ្នោតដោយខ្លួនឯង។ ចាប់ពីឆ្នាំ១៩៩៨ មកដល់បច្ចុប្បន្ន គ.ជ.ប បានរៀបចំការបោះឆ្នោតយ៉ាងទៀងទាត់ ទាំងសកល ទាំងអសកល ចំនួន ១៦ លើករួចមកហើយ។ ឯកឧត្តមបានបន្តថា ការរៀបចំការបោះឆ្នោតដំបូង

មានជួបបញ្ហាស្មុគស្មាញជាច្រើន ជាពិសេសបញ្ហាអសន្តិសុខក្នុងដំណើរការបោះឆ្នោត និងបរិយាកាសក្រោយការបោះឆ្នោត មានការតវ៉ាទៅនឹងលទ្ធផលនៃការបោះឆ្នោត។ ប៉ុន្តែប៉ុន្មានអាណត្តិចុងក្រោយនេះ ដំណើរការនៃការបោះឆ្នោតបានប្រព្រឹត្តទៅដោយរលូនល្អ មិនមានបញ្ហាអ្វីនោះទេ។

ឯកឧត្តមប្រធាន គ.ជ.ប បានជម្រាបជូនបន្តទៀតថា ជាទូទៅការរៀបចំការបោះឆ្នោតមាន ៤ ដំណាក់កាល ហើយឯកឧត្តមក៏បានពន្យល់ដោយសង្ខេបនូវដំណាក់កាលនីមួយៗនៃដំណើរការរៀបចំការបោះឆ្នោត៖

- ដំណាក់កាលពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត
- ដំណាក់កាលចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ



**សកម្មភាពក្នុងជំនួបពិភាក្សា**

- ដំណាក់កាលឃោសនាបោះឆ្នោត
- ដំណាក់កាលបោះឆ្នោត រាប់សន្លឹកឆ្នោត បែងចែកអាសនៈ និងប្រកាសលទ្ធផលនៃការបោះឆ្នោត។

ចំពោះការដោះស្រាយបណ្តឹងពាក់ព័ន្ធនឹងការបោះឆ្នោត ឯកឧត្តម **ប្រាជ្ញ ចន្ទ** បានជម្រាបជូនថា មាន ៤ ថ្នាក់ គឺនៅគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត (គឃ.សប) នៅគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (គធ.ខប) នៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) និងចុងក្រោយនៅក្រុមប្រឹក្សាធម្មនុញ្ញ។

ឯកឧត្តមបានជម្រាបជូនបន្តទៀតថា ការបោះឆ្នោតនៅកម្ពុជា គឺមានរៀបចំឱ្យមានការចូលរួមផ្តល់អនុសាសន៍លើ



**(រូបខាងស្តាំ)ឯកឧត្តម ប្រាជ្ញ ចន្ទ ប្រធាន គ.ជ.ប និងឯកឧត្តម អ៊ីតធីផន ប៊ុនប្រាខង ប្រធាន គ.ជ.ប នៃព្រះរាជាណាចក្រថៃ**

បទបញ្ញា និងនីតិវិធីនៃការបោះឆ្នោតពីបណ្តាភាគីពាក់ព័ន្ធទាំងអស់រួមមាន គណបក្សនយោបាយ អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធនឹងការបោះឆ្នោត។

ចំពោះការត្រៀមរៀបចំសម្ភារសម្រាប់ការបោះឆ្នោត ឯកឧត្តម **ប្រាជ្ញ ចន្ទ** បានមានប្រសាសន៍ថា សម្ភារបោះឆ្នោតបានដឹកជញ្ជូនទៅដល់គោលដៅអស់ហើយ។ តំបន់ខ្លះត្រូវដឹកជញ្ជូនសម្ភារបោះឆ្នោតតាមយន្តហោះ តំបន់ខ្លះទៀតត្រូវដឹកជញ្ជូនតាមដំរី ដោយសារភ្លៀងជោគជាំ ផ្លូវពិបាកធ្វើដំណើរ និងត្រូវឆ្លងកាត់ទឹកថែមទៀត។

ឯកឧត្តម **ប្រាជ្ញ ចន្ទ** បានមានប្រសាសន៍បន្តទៀតថា គ.ជ.ប កម្ពុជា អនុវត្តសមត្ថកិច្ចរបស់ខ្លួនប្រកបដោយឯករាជ្យផ្អែកលើច្បាប់ជាធរមាន ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីការបោះឆ្នោត រួមទាំងបទបញ្ញា និងនីតិវិធីសម្រាប់ការបោះឆ្នោត។

ក្រោយពីបានស្តាប់ប្រសាសន៍របស់ ឯកឧត្តមប្រធាន គ.ជ.ប រួចមក ឯកឧត្តម **អ៊ីតធីផន ប៊ុនប្រាខង** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះព័ត៌មានដែលទទួលបាននៅពេល



**សកម្មភាពក្នុងជំនួបពិភាក្សា**

នេះ អំពីប្រវត្តិនៃការបោះឆ្នោតនៅព្រះរាជាណាចក្រកម្ពុជា និងកិច្ចដំណើរការនៃការរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧។ ឯកឧត្តមក៏បានចែករំលែកព័ត៌មានអំពីការបោះ-ឆ្នោតនៅព្រះរាជាណាចក្រថៃ ថា ព្រះរាជាណាចក្រថៃ ធ្លាប់រៀបចំការបោះឆ្នោត ចំនួន ៧២ លើក រួចមកហើយ ដែលកាលមុនការរៀបចំការបោះឆ្នោតស្ថិតនៅក្រោមការរៀបចំរបស់ក្រសួងមហាផ្ទៃ។ ក្រោយមក គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវបានបង្កើតឡើង ដែលមានអាយុកាល ២៥ ឆ្នាំ ហើយមកដល់ពេលនេះ។ ក្នុងអាណត្តិនៃការគ្រប់គ្រងរបស់ ឯកឧត្តម **អ៊ីតធីផន ប៊ុនប្រាខង** គឺបានរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ចំនួន ២ លើក នៅឆ្នាំ២០១៩ និងនៅថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២៣នេះ។ ឯកឧត្តមបានបន្តថា ព្រះរាជាណា-ចក្រថៃ ក៏មានការបោះឆ្នោតថ្នាក់មូលដ្ឋានផងដែរ។ ចំពោះបច្ចេក-ទេសពាក់ព័ន្ធទៅនឹងការរៀបចំការបោះឆ្នោតមានផ្នែកខ្លះស្រដៀងគ្នា និងផ្នែកខ្លះមានភាពខុសគ្នាពីព្រះរាជាណាចក្រកម្ពុជា។ នៅព្រះរាជាណាចក្រថៃ មិនមានធ្វើការចុះឈ្មោះបោះឆ្នោតនោះទេ គឺបញ្ជីបោះឆ្នោតយកចេញពីក្រសួងមហាផ្ទៃ។ ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនមានភាពខុសគ្នាខ្លះ រីឯការឃោសនាបោះឆ្នោតស្រដៀងគ្នានៅព្រះ-រាជាណាចក្រកម្ពុជា។ ការបោះឆ្នោតបើកដំណើរការចាប់ពីម៉ោង ៨:០០ព្រឹក រហូតដល់ម៉ោង ៥:០០ល្ងាច ហើយការរាប់សន្លឹក-ឆ្នោត គឺរាប់នៅនឹងការិយាល័យបោះឆ្នោតតែម្តង។ ចំពោះការផ្សព្វផ្សាយលទ្ធផលនៃការបោះឆ្នោតក្នុងឆ្នាំ២០២៣ នេះ គ.ជ.ប ថៃ ផ្សាយបានលឿនជាងការបោះឆ្នោតក្នុងឆ្នាំ២០១៩។ ឯកឧត្តមមានចំណាប់អារម្មណ៍ជាខ្លាំងចង់ឃើញការផ្សព្វផ្សាយលទ្ធផល



**សកម្មភាពថតរូបអនុស្សាវរីយ៍**

នៃការបោះឆ្នោតរបស់ គ.ជ.ប កម្ពុជា ផងដែរ ហើយសង្ឃឹមថានឹងបានដកស្រង់បទពិសោធន៍ពីកម្ពុជា។ ឯកឧត្តមបន្តថា បន្ទាប់ពីបញ្ចប់បេសកកម្មនេះ ឯកឧត្តមចង់ឱ្យមានជំនួបពិភាក្សាគ្នាជាបន្តទៀតដើម្បីផ្លាស់ប្តូរបទពិសោធន៍រវាង គ.ជ.ប ថៃ និង គ.ជ.ប កម្ពុជា ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងបន្តជួបគ្នាក្នុងចំណោម គ.ជ.ប នៃបណ្តាប្រទេសក្នុងសមាគមអាស៊ាន។ ឯកឧត្តម **អ៊ីតធីផន ប៊ុនប្រាខង** សន្យាថា នឹងអញ្ជើញប្រធាន គ.ជ.ប កម្ពុជា ទៅទស្សនកិច្ចនៅព្រះរាជាណាចក្រថៃវិញម្តង។

ឯកឧត្តម **ប្រាជ្ញ ចន្ទ** បានថ្លែងអំណរគុណ និងទទួលយកចំពោះការលើកឡើងរបស់ ឯកឧត្តម **អ៊ីតធីផន ប៊ុនប្រាខង** ជាពិសេសទំនាក់ទំនងទ្វេភាគីរវាង គ.ជ.ប ថៃ និង គ.ជ.ប កម្ពុជា និងឈានទៅជំនួបពិភាក្សាគ្នារវាង គ.ជ.ប ទាំងអស់ក្នុងបណ្តាប្រទេសនៃសមាគមអាស៊ាន។

ជំនួបពិភាក្សាផ្លាស់ប្តូរបទពិសោធន៍ការងារ បានប្រព្រឹត្តទៅអស់រយៈពេលមួយម៉ោង ដោយភាពស្និទ្ធស្នាល និងយោគយល់គ្នាយ៉ាងជ្រាលជ្រៅ៕

## សរុបព្រឹត្តិការណ៍ឃោសនាបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ រយៈពេល ២១ ថ្ងៃ

នារសៀលថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២៣ វេលាម៉ោង ៤:០០ នៅសាលសន្និសីទរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) មានបើកកិច្ចប្រជុំជាមួយភាគីពាក់ព័ន្ធ ក្រោមអធិបតីភាព ឯកឧត្តម **ហង្ស ពុទ្ធា** សមាជិក គ.ជ.ប និងជា




**ឯកឧត្តម ហង្ស ពុទ្ធា សមាជិក និងជាប្រធានក្រុមអ្នកនាំពាក្យ គ.ជ.ប**

ប្រធានក្រុមអ្នកនាំពាក្យ គ.ជ.ប និងជាប្រធានដឹកនាំកិច្ចប្រជុំ ដើម្បីផ្សព្វផ្សាយអំពីព្រឹត្តិការណ៍នៃការឃោសនាបោះឆ្នោត ជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ រយៈពេល ២១ ថ្ងៃ និងការបិទផ្សាយបញ្ជីបោះឆ្នោត និងលេខកូដការិយាល័យបោះឆ្នោត នៅតាមការិយាល័យបោះឆ្នោត។

ឯកឧត្តម **ហង្ស ពុទ្ធា** បានមានប្រសាសន៍ថា រយៈពេល ២១ ថ្ងៃ នៃការឃោសនារកសំឡេងឆ្នោត គណបក្សនយោបាយ ដែលបានចុះបញ្ជីឈ្មោះបោះឆ្នោត និងមានបញ្ជីបេក្ខជន នៅតាមមណ្ឌលរាជធានី ខេត្ត បានធ្វើសកម្មភាពយ៉ាងគគ្រឹក-គគ្រេងក្នុងបរិយាកាសល្អ។ គណបក្សនយោបាយនីមួយៗ បានធ្វើសកម្មភាពឃោសនាបោះឆ្នោតតាមមធ្យោបាយផ្សេងៗ និងតាមលទ្ធភាពរៀងៗខ្លួន ដែលមានជាអាទិ៍ ការជួបប្រជុំជាមួយអ្នកគាំទ្រ និងសកម្មជននៅតាមទីសាធារណៈ និងតាមទីស្នាក់ការគណបក្សនយោបាយ ការចុះសួរសុខទុក្ខប្រជាពលរដ្ឋតាមខ្នងផ្ទះ ការប្រគំតន្ត្រី ការបញ្ចាំងស្លាយវីដេអូតាមទីសាធារណៈ ការចែក



**ភាគីពាក់ព័ន្ធចូលរួមក្នុងកិច្ចប្រជុំ**

ខិត្តប័ណ្ណតាមខ្នងផ្ទះ និងតាមផ្សារ ការចាក់មេក្រូផ្សព្វផ្សាយនៅតាមទីស្នាក់ការគណបក្សនយោបាយ និងចាក់មេក្រូចល័តតាមភូមិជាដើម។ ឯកឧត្តមបានបន្តថា ក្នុងចំណោមគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតទាំង ១៨ មានគណបក្សចំនួន ១៦ បានធ្វើសកម្មភាពហែក្បួនឃោសនាបោះឆ្នោតនៅតាមមណ្ឌលបោះឆ្នោតនានា ដែលខ្លួនមានបញ្ជីបេក្ខជនឈរឈ្មោះ ក្នុងនោះ គ.ជ.ប បានកត់សម្គាល់ឃើញថា ក្បួនឃោសនារបស់គណបក្សប្រជាជនកម្ពុជា មានទំហំធំ និងមានអ្នកចូលរួមច្រើនជាងគេ។ គ.ជ.ប សង្កេតឃើញថា រយៈពេល ២១ ថ្ងៃ នេះ មានអ្នកចូលរួមឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយសរុប ២.២៣៦.៧៩៤ នាក់ ប្រើថយន្តឃោសនាមាន ៩៩.៧៩៤ គ្រឿង ទោចក្រយានយន្ត៧២២.៧៣៣ គ្រឿង ម៉ូតូកង់បី១០.២៤០ គ្រឿង គោយន្ត៣.៤៩១គ្រឿង កាណូត៨៥៧គ្រឿង និងទោចក្រយាន ៦២០ គ្រឿង។



**ភាគីពាក់ព័ន្ធចូលរួមក្នុងកិច្ចប្រជុំ**

លើសពីនេះ ក៏មានការផ្សព្វផ្សាយនូវសកម្មភាពឃោសនាបោះឆ្នោត និងសារនយោបាយរបស់គណបក្សនយោបាយនៅលើបណ្តាញព័ត៌មានសង្គមហ្វេសប៊ុក (FACEBOOK) ជារៀងរាល់ថ្ងៃផងដែរ។ ឯកឧត្តមបានមានប្រសាសន៍បន្តទៀតថា គ្រប់គណបក្សនយោបាយដែលធ្វើសកម្មភាពឃោសនាបោះឆ្នោត បានជូនដំណឹងមកគណៈកម្មការរាជធានី ខេត្តរៀបចំការបោះ-ឆ្នោត អំពីពេលវេលា និងទីតាំងដែលពួកគាត់ត្រូវធ្វើសកម្មភាពឃោសនា។ អាជ្ញាធរមូលដ្ឋាន បានខិតខំជួយសម្របសម្រួលដល់ការធ្វើសកម្មភាពឃោសនា ដូចជាការការពារទីតាំង ការរក្សាសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ ពិសេសបាន

ជួយសម្រួលចរាចរណ៍តាមដងផ្លូវនៅពេលមានការហែក្បួនឃោសនាជាដើម។ ឯកឧត្តមបានមានប្រសាសន៍បន្ថែមទៀតថា ក្នុងអំឡុងពេលនៃការឃោសនារកសំឡេងឆ្នោតនេះផងដែរ គណបក្សនយោបាយទាំង ១៨ មានឱកាសផ្សព្វផ្សាយដោយស្មើភាពគ្នានូវគោលនយោបាយ និងកម្មវិធីនយោបាយរបស់ខ្លួនទៅកាន់អ្នកបោះឆ្នោត តាមរយៈកម្មវិធីផ្សព្វផ្សាយគោលនយោបាយរបស់គណបក្សនយោបាយដែលរៀបចំដោយ គ.ជ.ប។ ការផ្សព្វផ្សាយនេះធ្វើឡើងតាមវិទ្យុ និងទូរទស្សន៍របស់រដ្ឋ និងព្រឹត្តិបត្រគោលនយោបាយរបស់គណបក្សនយោបាយ ដែលបោះពុម្ពផ្សាយដោយ គ.ជ.ប មានចំនួនពីរលេខ។

ជារួម ឯកឧត្តម **ហង្ស ពុទ្ធា** បានវាយតម្លៃថា រយៈពេល ២១ ថ្ងៃ នៃការឃោសនាបោះឆ្នោត បានប្រព្រឹត្តទៅដោយរលូន មានការយោគយល់អធ្យាស្រ័យគ្នាខ្ពស់ មានកិច្ចសហការពី



ភាគីពាក់ព័ន្ធមានចំណាប់អារម្មណ៍ និងសំណួរក្នុងកិច្ចប្រជុំ

បណ្ដាភាគីពាក់ព័ន្ធនានាបានល្អប្រសើរ ដែលរក្សាបាននូវសន្តិសុខ សុវត្ថិភាព និងសណ្ដាប់ធ្នាប់របៀបរៀបរយក្នុងមណ្ឌលបោះឆ្នោតនីមួយៗ។

ពាក់ព័ន្ធនឹងពាក្យបណ្ដឹង ឯកឧត្តម **ហង្ស ពុទ្ធា** បានជម្រាបជូនថា គិតត្រឹមថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២៣ គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត (គឃ.សប) បានទទួលពាក្យបណ្ដឹងពាក់ព័ន្ធនឹងការឃោសនាបោះឆ្នោត សរុបចំនួន ៣២ បណ្ដឹង។ ក្នុងចំណោមពាក្យបណ្ដឹងទាំងនោះ គឃ.សប បានធ្វើការដោះស្រាយតាមនីតិវិធី និងមានពាក្យបណ្ដឹងបន្តប្ដឹងមកគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត រួចបន្តមក គ.ជ.ប។



សកម្មភាពក្នុងកិច្ចប្រជុំ

ចំពោះការបិទបញ្ចប់ដំណើរការឃោសនាបោះឆ្នោត ឯកឧត្តម **ហង្ស ពុទ្ធា** បានជម្រាបជូនថា ថ្ងៃទី២១ ខែកក្កដា ជាថ្ងៃចុងក្រោយនៃការឃោសនាបោះឆ្នោត គ្រប់គណបក្សនយោបាយទាំងអស់ ត្រូវតែបញ្ឈប់សកម្មភាពរបស់ខ្លួនត្រឹមម៉ោង ១០ យប់ (ម៉ោង ១០ យប់ ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២៣)។ ជាមួយគ្នានេះដែរ ប្រព័ន្ធផ្សព្វផ្សាយត្រូវផ្អាកការផ្សព្វផ្សាយនូវសកម្មភាពនយោបាយ ឬអំពីគោលនយោបាយរបស់គណបក្សនយោបាយណាមួយ ឬខ្លឹមសារផ្សេងទៀត ដែលមានចរិតជាការឃោសនារកការគាំទ្រពីអ្នកបោះឆ្នោត។ ឯកឧត្តម **ហង្ស ពុទ្ធា** បន្តថា គ្រប់គណបក្សនយោបាយ ត្រូវប្រមូលយកស្លាកសញ្ញា និងសម្ភារឃោសនាផ្សេងទៀតរបស់ខ្លួន ដែលស្ថិតនៅក្នុងរង្វង់ ១០០ ម៉ែត្រ ពីការិយាល័យបោះឆ្នោត យ៉ាងយូរបំផុតនៅថ្ងៃបញ្ចប់ការឃោសនានេះ លើកលែងតែស្លាកសញ្ញាដែលមាននៅទីស្នាក់ការអចិន្ត្រៃយ៍។

ពាក់ព័ន្ធនឹងការបិទផ្សាយបញ្ជីបោះឆ្នោត និងលេខកូដការិយាល័យបោះឆ្នោតនៅតាមការិយាល័យបោះឆ្នោត ឯកឧត្តម



ភាគីពាក់ព័ន្ធមានចំណាប់អារម្មណ៍ និងសំណួរក្នុងកិច្ចប្រជុំ

**ហង្ស ពុទ្ធា** បានជម្រាបជូនដែរថា នៅមួយថ្ងៃមុនថ្ងៃបោះឆ្នោត គឺនៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២៣ ប្រធានការិយាល័យបោះ-ឆ្នោត (គ.ក.ប) ត្រូវចាត់ឱ្យបិទផ្សាយលេខកូដការិយាល័យបោះ-ឆ្នោត និងបញ្ជីបោះឆ្នោតផ្លូវការ ឆ្នាំ២០២២ ចំនួន ១ ច្បាប់ នៅមុខទីតាំងការិយាល័យបោះឆ្នោត។ ការបិទផ្សាយនេះត្រូវជានាថា អាចផ្តល់លក្ខណៈងាយស្រួលចំពោះប្រជាពលរដ្ឋ ពិសេសជនមានពិការភាព (ជនពិការជិះរទេះ) ក្នុងការមកពិនិត្យឈ្មោះរបស់ខ្លួនតាមការិយាល័យបោះឆ្នោត និងត្រូវជានាថាបញ្ជីនេះ ត្រូវបានបិទនៅទីតាំងដែលមិនមានការជ្រាបលេច ជាហេតុបណ្តាលឱ្យសើម ឬប៉ះពាល់ដល់បញ្ជីបោះឆ្នោត។ ឯកឧត្តមបន្តទៀតថា ក្រៅពីការបិទផ្សាយនៅតាមការិយាល័យបោះឆ្នោត គ.ជ.ប ក៏បានបង្ហោះផងដែរនូវបញ្ជីបោះឆ្នោតនេះនៅលើគេហទំព័រ "voterlist.nec.gov.kh" និងនៅលើ App "NEC KH"។

មានសំណួរមួយចំនួនរបស់ភាគីពាក់ព័ន្ធបានលើកឡើង ហើយតំណាង គ.ជ.ប ក៏បានឆ្លើយបំភ្លឺដូចតទៅ៖

- អំពីពាក្យបណ្តឹងក្នុងអំឡុងពេលឃោសនាបោះឆ្នោតនេះ តាមនីតិវិធីដំបូងត្រូវដាក់ពាក្យបណ្តឹងនៅ គឃ.សប រួចបន្តមកគណៈកម្មការរាជធានី ខេត្តរៀបចំការបោះ-ឆ្នោត បន្តមក គ.ជ.ប និងចុងក្រោយនៅក្រុមប្រឹក្សាធម្មនុញ្ញ។ អ្នកដែលត្រូវបានគេប្តឹងមាន ២១ នាក់ ហើយការដោះស្រាយបណ្តឹងនោះ ត្រូវបានគណៈ-កម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត ពិន័យជាប្រាក់ និងដកសិទ្ធិបោះឆ្នោត សរុបចំនួន ១៧ នាក់
- ចំពោះអ្នកសង្កេតការណ៍បោះឆ្នោតអន្តរជាតិមានចំនួន ៤២៣ នាក់ មកពី ៥៩ ស្ថាប័ន។ រីឯអ្នកសង្កេត-ការណ៍បោះឆ្នោតជាតិមាន ៨៩.៥៦២ នាក់ មកពី ១៣៤ ស្ថាប័ន
- មកដល់ពេលនេះសម្ភារបោះឆ្នោតបានទៅដល់ គឃ.សប អស់ហើយ ថ្ងៃស្អែកឃុំ សង្កាត់ត្រូវបញ្ជូនទៅការិយា-ល័យបោះឆ្នោត ដើម្បីឱ្យមន្ត្រីបោះឆ្នោតរៀបចំការិយា-ល័យបោះឆ្នោត។ នៅរដូវនេះជារដូវភ្លៀង ជាហេតុធ្វើឱ្យការិយាល័យបោះឆ្នោត ចំនួន ១០ ត្រូវបានផ្លាស់ប្តូរទីតាំង។ ចំពោះការការពារសន្តិសុខ គ.ជ.ប បានត្រៀមកម្លាំងរួចរាល់ហើយ
- ឆ្លើយទៅនឹងសំណួរដែលគណបក្សនយោបាយមិនបានហែក្បួនឃោសនាបោះឆ្នោតនោះ គឺគណបក្សធម្មាធិបតេយ្យ និងគណបក្សបំណងពលរដ្ឋ។

ជាចុងក្រោយក្នុងនាម ឯកឧត្តម **ប្រាជ្ញ ចន្ទ** ប្រធាន គ.ជ.ប និងឯកឧត្តម **ហង្ស ពុទ្ធា** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះតំណាងក្រសួង ស្ថាប័ន គណបក្សនយោបាយ សមាគម អង្គការមិនមែនរដ្ឋាភិបាល និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ដែលបានចំណាយពេលវេលាអញ្ជើញចូលរួមក្នុងកិច្ចប្រជុំដ៏មានសារៈសំខាន់នេះ។ ឯកឧត្តមសង្ឃឹមជឿជាក់យ៉ាងមុតមាំថា តំណាងភាគីពាក់ព័ន្ធទាំងអស់ ពិសេសគ្រប់គណបក្សនយោបាយនឹងអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត និងសេចក្តីណែនាំផ្សេងទៀតជាធរមាន។ ឯកឧត្តមបានអំពាវនាវផងដែរចំពោះប្រជាពលរដ្ឋសូមត្រៀមឯកសារដែលរួមមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (អ.ខ) ឬឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត (ឯ.អ) និងសូមទៅបោះឆ្នោតទាំងអស់គ្នា ដោយគ្មានការភ័យខ្លាច ដោយសេរី និងជានាការសម្ងាត់ ដើម្បីអភិវឌ្ឍសង្គមជាតិរបស់យើង។

ក្នុងកិច្ចប្រជុំជាមួយភាគីពាក់ព័ន្ធនឹងការបោះឆ្នោតនេះ មានការអញ្ជើញចូលរួមពីតំណាងក្រុមប្រឹក្សាធម្មនុញ្ញ អគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភា ក្រសួងមហាផ្ទៃ ក្រសួងសង្គមកិច្ច អតីត-យុទ្ធជន និងយុវនីតិសម្បទា ក្រសួងព័ត៌មាន អគ្គស្នងការដ្ឋាន-នគរបាលជាតិ កងរាជអាវុធហត្ថលើផ្ទៃប្រទេស មន្ត្រីស្ថានទូតជប៉ុន គណបក្សនយោបាយ សមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងអ្នកសារព័ត៌មាន ចំនួនប្រមាណ ៧០ នាក់៕

# ក្រុមអ្នកនាំពាក្យ គ.ជ.ប ជួបជាមួយក្រុមអ្នកសង្កេតការណ៍បោះឆ្នោតអន្តរជាតិ មកពីប្រទេសជប៉ុន

នារសៀលថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២៣ វេលាម៉ោង ២:០០ នៅទីស្តីការគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ឯកឧត្តម **ហង្ស ពុទ្ធា** សមាជិក គ.ជ.ប និងជាប្រធានក្រុមអ្នកនាំពាក្យ គ.ជ.ប បានទទួលជួបលោក **ណាអូតូ សាកាហ្គុជិ** (Mr. Naoto Sakaguchi) ប្រធានក្រុមអ្នកសង្កេតការណ៍បោះឆ្នោតអន្តរជាតិមកពីប្រទេសជប៉ុនរួមទាំងសហការី ចំនួន ៧ (ប្រាំពីរ) រូប ដើម្បីសម្តែងការគួរសម និងស្វែងយល់ពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣។



ឯកឧត្តម ហង្ស ពុទ្ធា សមាជិក និងជាប្រធានក្រុមអ្នកនាំពាក្យ គ.ជ.ប

ជាកិច្ចចាប់ផ្តើម ឯកឧត្តម **ហង្ស ពុទ្ធា** សមាជិក និងជាប្រធានក្រុមអ្នកនាំពាក្យ គ.ជ.ប បានមានមតិស្វាគមន៍ក្រុមអ្នកសង្កេតការណ៍បោះឆ្នោតអន្តរជាតិមកពីប្រទេសជប៉ុន ដែលបានអញ្ជើញមកចូលរួមសង្កេតមើលការបោះឆ្នោតនៅកម្ពុជា ដែលប្រព្រឹត្តទៅនៅថ្ងៃអាទិត្យ ទី២៣ ខែកក្កដា ឆ្នាំ២០២៣។

លោក **ណាអូតូ សាកាហ្គុជិ** បានថ្លែងអំណរគុណដល់ក្រុមអ្នកនាំពាក្យ គ.ជ.ប ដែលបានចំណាយពេលទទួលជួបគណៈប្រតិភូសង្កេតការណ៍បោះឆ្នោតអន្តរជាតិមកពីប្រទេសជប៉ុន ក្នុងខណៈដែលគ.ជ.បមានការមមាញឹករៀបចំការបោះឆ្នោត។ លោក **ណាអូតូ សាកាហ្គុជិ** បានរំលឹកអំពីការងាររបស់លោកធ្លាប់ធ្វើនៅប្រទេសកម្ពុជាក្នុងនាមជាអ្នកស្ម័គ្រចិត្តកាលពី ៣១ ឆ្នាំកន្លងមកនាសម័យកាលអ៊ុនតាក់ និងលោកធ្លាប់ជាសមាជិករដ្ឋសភាជប៉ុន ចំនួន ២ អាណត្តិ។ លោកបានបញ្ជាក់ថា ការចូលរួមរបស់គណៈប្រតិភូសង្កេតការណ៍បោះឆ្នោតអន្តរជាតិមកពីប្រទេសជប៉ុននៅពេលនេះ មិនមែនចូលរួមក្នុងនាមរដ្ឋាភិបាលជប៉ុនទេ គឺក្រុមរបស់លោកមកតាមអង្គការមិនមែនរដ្ឋាភិបាល ដែលមានទីស្នាក់ការនៅប្រទេសជប៉ុន ហើយជំនួបនៅពេលនេះលោកចង់ស្វែងយល់ និងមានសំណួរមួយចំនួនពាក់ព័ន្ធនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ឆ្នាំ២០២៣ នេះ។

ឯកឧត្តម **ហង្ស ពុទ្ធា** បានជម្រាបជូនគណៈប្រតិភូ អំពីប្រវត្តិនៃការបោះឆ្នោតនៅកម្ពុជាថា នៅឆ្នាំ១៩៩៣ គឺជាការបោះឆ្នោតជ្រើសរើសសភាធម្មនុញ្ញ ដែលការបោះឆ្នោតនោះ បានរៀបចំដោយអាជ្ញាធរបណ្តោះអាសន្ននៃអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា ហៅកាត់ថា "UNTAC"។ ឯកឧត្តមបានបន្តថា នៅឆ្នាំ១៩៩៨ ប្រទេសកម្ពុជាបានរៀបចំការបោះឆ្នោតដោយខ្លួនឯង និងបានរៀបចំការបោះឆ្នោតជាបន្តបន្ទាប់មកទៀតរហូតមកដល់បច្ចុប្បន្ន។ រហូតមកទល់ពេលនេះ គ.ជ.ប បានរៀបចំការបោះឆ្នោតដោយខ្លួនឯងយ៉ាងទៀងទាត់ ទាំងសកល និង



លោក ណាអូតូ សាកាហ្គុជិ ប្រធានក្រុមអ្នកសង្កេតការណ៍បោះឆ្នោតអន្តរជាតិមកពីប្រទេសជប៉ុន



**សកម្មភាពក្នុងជំនួបពិភាក្សា**

អសកល ចំនួន ១៦ លើក រួចមកហើយ។ ឯកឧត្តមក៏បានលើកឡើងអំពីដំណាក់កាលសំខាន់ៗទាំង ៤ នៃការបោះឆ្នោតដើម្បីឱ្យក្រុមអ្នកសង្កេតការណ៍អន្តរជាតិបានយល់ ដែលរួមមាន៖

- ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត
- ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ
- ការឃោសនាបោះឆ្នោត និង
- ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការប្រកាសលទ្ធផលនៃការបោះឆ្នោត។

ក្នុងជំនួបដ៏មានសារៈសំខាន់នេះ ឯកឧត្តម **ហង្ស ពុទ្ធា** បានពន្យល់បន្ថែមអំពីតួនាទី ភារកិច្ច និងក្រមសីលធម៌របស់អ្នកសង្កេតការណ៍បោះឆ្នោតនៅកម្ពុជាផងដែរ។

ក្រុមអ្នកសង្កេតការណ៍បោះឆ្នោតអន្តរជាតិបានលើកឡើងនូវសំណួរមួយចំនួនដូចជា៖

- ចំនួនអ្នកសង្កេតការជាតិ និងអន្តរជាតិ
- ការចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ដែល គ.ជ.ប បានសម្រេចបដិសេធ ចំនួន ២ គណបក្ស
- សកម្មភាពឃោសនាបោះឆ្នោត ជាដើម។

ក្រុមអ្នកនាំពាក្យ គ.ជ.ប បានឆ្លើយតបម្តងមួយសំណួរៗ ដោយបានបញ្ជាក់ថា គិតត្រឹមថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២៣ គ.ជ.ប បានទទួលអ្នកសង្កេតការណ៍បោះឆ្នោតអន្តរជាតិជាង ៦០០ នាក់ បើប្រៀបធៀបនឹងការបោះឆ្នោតសកលកន្លងមក មានចំនួនជាង ៥០០ នាក់ តែប៉ុណ្ណោះ។ ចំពោះហេតុផលដែលគណបក្សនយោបាយ ចំនួន ២ ដែលត្រូវបាន គ.ជ.ប និងក្រុមប្រឹក្សាធម្មនុញ្ញបដិសេធ ដោយសារគណបក្សមិនបានបំពេញលក្ខខណ្ឌតាមច្បាប់ និងតាមនីតិវិធី។ រីឯការឃោសនាបោះឆ្នោតគណបក្សនយោបាយនីមួយៗ កំពុងធ្វើសកម្មភាពតាមលទ្ធភាពរបស់ខ្លួនស្របតាមនីតិវិធីឃោសនាបោះឆ្នោត ដែលគិតមកដល់ពេលនេះមានរយៈពេល ២០ ថ្ងៃ ហើយ។

ឯកឧត្តម **ហង្ស ពុទ្ធា** បានបញ្ជាក់បន្ថែមជូនគណៈប្រតិភូថា បើនៅមានចម្ងល់ពាក់ព័ន្ធនឹងការបោះឆ្នោត គឺអាចទាក់ទងជាមួយក្រុមអ្នកនាំពាក្យ គ.ជ.ប ជាបន្តទៀត ដើម្បីសាកសួរបន្ថែមអំពីការបោះឆ្នោតនៅកម្ពុជា។



**សកម្មភាពថតរូបអនុស្សាវរីយ៍**

ចុងបញ្ចប់នៃកិច្ចពិភាក្សា ឯកឧត្តម **ហង្ស ពុទ្ធា** បានថ្លែងអរគុណដល់រដ្ឋាភិបាលជប៉ុន ដែលបានផ្តល់ជំនួយដល់ គ.ជ.ប នាពេលកន្លងមក។ ឯកឧត្តមសង្ឃឹមថា តាមរយៈអ្នកសង្កេតការណ៍បោះឆ្នោតអន្តរជាតិមកពីប្រទេសជប៉ុន ដែលមានលោក **ណាអូតូ សាកាហ្គូជិ** នឹងជួយជម្រាបអំពីតម្រូវការរបស់ គ.ជ.ប ជូនរដ្ឋាភិបាលជប៉ុន ដើម្បីផ្តល់ជំនួយបន្ថែមទៀត ដើម្បីឱ្យ គ.ជ.ប រៀបចំការចុះឈ្មោះបោះឆ្នោតឡើងវិញ នៅឆ្នាំ២០២៦ ដោយហេតុថាសម្ភារចុះឈ្មោះបោះឆ្នោតដែលបានប្រើមានរយៈពេល ១០ ឆ្នាំ មកហើយ។

ជំនួបពិភាក្សាបានប្រព្រឹត្តទៅអស់រយៈពេលជាង ២ ម៉ោង ប្រកបដោយការយោគយល់ និងស្និទ្ធស្នាល។

រៀបរៀង និងបោះពុម្ពផ្សាយដោយ
គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ទីស្តីការ គ.ជ.ប វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរសព្ទ (Tel) : (+855) 23 235 271
អ៊ីមែល (Email): info@nec.gov.kh
Website: www.nec.gov.kh, voterlist.nec.gov.kh
Facebook/Youtube: National Election Committee
APP: NEC KH, CamNEC News